# ១០ យ៉ាងដែលអ្នកគួដឹងអំពីវ៉ាក់សាំងបង្ការជម្ងឺ COVID-១៩

## 1 វ៉ាក់សាំងជួយបញ្ឈប់ការរាលដាលនៃជម្ងឺ COVID-១៩

វ៉ាក់សាំងគឺជាវិធីដែលមានសុវត្ថិភាពនិងមានប្រសិទ្ធភាពក្នុងការបង្ការជំងឺនិងជួយសង្គ្រោះជីវិតមនុស្ស។ នៅពេលដែលយើងចាក់វ៉ាក់សាំងយើងមិនត្រឹមតែការពារខ្លួនយើងប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ការពារដល់អ្នកដែលនៅជុំវិញយើងដូចជាសមាជិកគ្រួសារនិងមិត្តភក្តិរបស់យើងដែរ។ មនុស្សមួយចំនួនមិនអាចចាក់ថ្នាំបង្ការបានដោយសារគាត់មានបញ្ហាសុខភាពណាមួយប្រចាំខ្លួន។ ពួកគាត់គឺពឹងផ្អែកលើយើងទាំងអស់គ្នាឲ្យទៅចាក់វ៉ាក់សាំងដើម្បីជួយបន្ថយការរាលដាលនៃជម្ងឺផ្សេងៗ។

## 2 វ៉ាក់សាំងបង្ការជម្ងឺ COVID-១៩ ឥឡូវគឺមានផ្តល់ជូនហើយ

សាលាក្រុងឡុងប៊ិចនិងអង្គការដទៃទៀតបានចាប់ផ្តើមផ្តល់វ៉ាក់សាំងបង្ការជម្ងឺ COVID-១៩ ដល់ប្រជាជនជាច្រើនអ្នក ដោយចាប់ផ្តើមពីបុគ្គលិកសុខាភិបាល ហើយបន្ទាប់មកមនុស្សវ័យចំណាស់ អ្នកអប់រំ និងបុគ្គលិកធ្វើការផ្នែកម្ហូបអាហារ។ យើងនឹងបន្តចាក់វ៉ាក់សាំងបង្ការជម្ងឺ COVID-១៩ ជូនអ្នកគ្រប់គ្នាដែលចង់ចាក់ថ្នាំនេះ តាមរបៀបមួយដែលរក្សាភាពសមធម៌ តាមការណែនាំពីសហព័ន្ធនិងរដ្ឋ។

## 3 វ៉ាក់សាំងជួយរាងកាយរបស់យើងប្រយុទ្ធប្រឆាំងនឹងជំងឺ

វ៉ាក់សាំងមានតួនាទីសំខាន់ក្នុងការរក្សាសុខភាពរបស់យើង។ វ៉ាក់សាំងការពារយើងពីជំងឺធ្ងន់ធ្ងរនិងពេលខ្លះពីជំងឺដែលអាចបណ្តាលឱ្យស្លាប់បាន ដោយការត្រៀមប្រព័ន្ធការពាររាងកាយរបស់យើងឲ្យទទួលស្គាល់មេរោគមួយចំនួននិងប្រយុទ្ធប្រឆាំងនឹងការឆ្លង។ វ៉ាក់សាំងបង្ការជម្ងឺ COVID-១៩ ការពារយើងពីវីរុសដែលបណ្តាលឱ្យមានជម្ងឺ COVID-១៩ ដោយយើងមិនចាំបាច់កើតជម្ងឺនេះជាមុន។ ប្រសិនបើក្រោយមកអ្នកមានទំនាក់ទំនងជាមួយអ្នកដែលមានជម្ងឺ COVID-១៩ ប្រព័ន្ធការពាររាងកាយរបស់អ្នកនឹងការពារអ្នកមិនឱ្យធ្លាក់ខ្លួនឈឺ។

## 4 ភស្តុតាងបានបង្ហាញឲ្យឃើញថាវ៉ាក់សាំងបង្ការជម្ងឺ COVID-១៩ មានសុវត្ថិភាពនិងប្រសិទ្ធភាពក្នុងការប្រឆាំងជាមួយនឹងជម្ងឺ COVID-១៩

សុវត្ថិភាពគឺជាអាទិភាពសំខាន់បំផុតក្នុងការអនុម័តនូវវ៉ាក់សាំងណាមួយ។ ការស្រាវជ្រាវបានរកឃើញថាវ៉ាក់សាំងទាំងនេះមានសុវត្ថិភាពនិងអាចការពារមនុស្សពីការធ្លាក់ខ្លួនឈឺដោយជម្ងឺ COVID-១៩ បាន។ វ៉ាក់សាំងនេះមិនមានវីរុស COVID-១៩ នោះទេដូច្នេះមនុស្សម្នាក់ៗមិនអាចកើតជម្ងឺ COVID-១៩ ពីការចាក់វ៉ាក់សាំងបង្ការជម្ងឺ COVID-១៩ នេះឡើយ។

LONG BEACH HEALTH & HUMAN SERVICES

CITY OF LONG BEACH

## 5 ដើម្បីទទួលបាន នូវការចាក់វ៉ាក់សាំងពេញលេញនោះ, អ្នកត្រូវរង់ចាំពីរសប្តាហ៍ បន្ទាប់ពីការចាក់វ៉ាក់សាំង Pfizer ឬ Moderna ដូសទីពីរ របស់អ្នករួច ឬពីរសប្តាហ៍ បន្ទាប់ពីការចាក់វ៉ាក់សាំង Janssen ដូសទីមួយ របស់អ្នករួច។

អ្នកគួរតែត្រូវបានចាក់វ៉ាក់សាំង Pfizer ដូសទីពីរអោយ ក្នុងរយៈពេល ២១-៤២ ថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំង ដូសទីមួយរបស់អ្នក, ឬក្នុងរយៈពេល ២៨-៤២ ថ្ងៃ បន្ទាប់ពីការចាក់វ៉ាក់សាំង Moderna ដូសទីមួយរបស់អ្នក។ អ្នកនឹងមានការការពារយ៉ាងពេញលេញ បន្ទាប់ពីពីរសប្តាហ៍ នៃការបានទទួលនូវការចាក់វ៉ាក់សាំង Pfizer ឬ Moderna របស់អ្នក ឬពីរសប្តាហ៍បន្ទាប់ពីអ្នកទទួលបាននូវការចាក់វ៉ាក់សាំង Janssen ដូសទីមួយ។

## 6 អ្នកអាចចាក់វ៉ាក់សាំងបានទោះបីជាអ្នកធ្លាប់កើតជម្ងឺ COVID-១៩ ពីមុនមកក៏ដោយ

មានការណែនាំឱ្យគ្រប់គ្នាដែលអាចទៅចាក់ថ្នាំបង្ការចម្ងឺ COVID-១៩ បានគួទៅចាក់។ នេះគឺរួមទាំងអ្នកដែលធ្លាប់កើតជម្ងឺ COVID-១៩ រួចហើយ ពីព្រោះគ្រប់គ្នាអាចឆ្លងជម្ងឺ COVID-១៩ ច្រើនជាងមួយដង។ ដោយសារជម្ងឺ COVID-១៩ អាចបណ្តាលឱ្យមនុស្សធ្លាក់ខ្លួនឈឺធ្ងន់ គឺជាការសំខាន់ណាស់ដែលសូម្បីតែអ្នកដែលធ្លាប់កើតជម្ងឺ COVID-១៩ ពីមុនមកក៏គួតែទៅចាក់វ៉ាក់សាំងការពារដែរ។

## 7 អ្នកអាចមានផលប៉ះពាល់បណ្តោះអាសន្នខ្លះពីវ៉ាក់សាំង

បន្ទាប់ពីចាក់ថ្នាំរួចគឺជារឿងធម្មតាទេដែលមនុស្សមួយចំនួននឹងអាចឈឺចាប់ត្រង់ដៃ ក្តៅខ្លួន អស់កម្លាំង ឬឈឺក្បាល។ ផលរំខានទាំងនេះច្រើនតែបាត់ទៅវិញបន្ទាប់ពី ១ ឬ ២ ថ្ងៃ។

## 8 យើងនៅតែត្រូវពាក់ម៉ាស់និងចាត់វិធានការផ្សេងៗដើម្បីរក្សាសុវត្ថិភាព

ប្រសិនបើអនុវត្តព្រមៗគ្នា ការចាក់វ៉ាក់សាំងបង្ការជម្ងឺ COVID-១៩ រួមជាមួយនឹងជំហានផ្សេងៗទៀតដែលផ្តោតទៅលើការការពារខ្លួនយើងនិងអ្នកដទៃ នឹងផ្តល់ការការពារល្អបំផុតពីជម្ងឺ COVID-១៩។ វ៉ាក់សាំងជួយឱ្យរាងកាយរបស់យើងត្រៀមខ្លួនប្រយុទ្ធនឹងវីរុសប្រសិនបើយើងមានការប៉ះពាល់នឹងមេរោគនេះនៅពេលអនាគត។ ជំហានផ្សេងទៀតដូចជាការពាក់របាំងមុខនិងការរក្សាគម្លាតរាងកាយពីគ្នាទៅវិញទៅមកនឹងជួយកាត់បន្ថយការចម្លងមេរោគ។

## 9 វ៉ាក់សាំងបង្ការជម្ងឺ COVID-១៩ គឺផ្តល់ជូនដោយមិនគិតថ្លៃទេ

អ្នកមិនមានការចំណាយលើការចាក់វ៉ាក់សាំងបង្ការជម្ងឺ COVID-១៩ នោះឡើយ។

## 10 អ្នកអាចស្វែងដឹងថាតើពេលណាបានដល់វេនអ្នកទៅចាក់ថ្នាំ

យើងខ្ញុំទទួលស្គាល់ថាមិនមែនមនុស្សគ្រប់គ្នានឹងអាចទទួលបាននូវវ៉ាក់សាំងបង្ការចម្ងឺ COVID-១៩ ភ្លាមៗក្នុងពេលតែមួយបាននោះទេ។ អ្នកអាចទទួលការជូនដំណឹងនៅពេលដែលដល់វេនអ្នកត្រូវទៅចាក់វ៉ាក់សាំងដោយចុះឈ្មោះនៅលើគេហទំព័រ MyTurn.ca.gov ឬទូរស័ព្ទទៅលេខ (៥៦២) ៥៧០-៤៦៣៦។

LONG BEACH HEALTH & HUMAN SERVICES

CITY OF LONG BEACH

To request this information in an alternative format or to request a reasonable accommodation, please contact Health and Human Services at 562.570.7177. A minimum of three (3) business days is requested to ensure availability. Reasonable attempts will be made to accommodate request made within less than three (3) business days.